**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ពុធ ៩ កើត ខែ អស្សុជ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សិក្ខាសាលាស្តីពី "ប្រព័ន្ធអេកូឡូស៊ីថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)"

នាព្រឹកថ្ងៃ ពុធ ទី ១ ខែ តុលា ឆ្នាំ ២០២៥ នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ដែលជាប្រតិបត្តិករនៃថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) បានរៀបចំសិក្ខាសាលាស្តីពី **"ប្រព័ន្ធអេកូឡូស៊ីថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ដោយមានការអញ្ជើញចូលរួមពីតួអង្គពីវិស័យសាធារណៈ វិស័យឯកជន និង ដៃគូអភិវឌ្ឍពាក់ព័ន្ធនានា ប្រមាណ ១៥០ នាក់។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត តាំង ងួនលី** នាយកប្រតិបត្តិមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានផ្តល់កិត្តិយសថ្លែងសុន្ទរកថាស្វាគមន៍ មុននឹងឈានដល់ការផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ថ្លែងសុន្ទរកថាបើកដោយ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"។ ជាកិច្ចបន្ទាប់ តំណាងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានធ្វើបទបង្ហាញស្តីពី "ប្រព័ន្ធអេកូឡូស៊ីថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា", "ប្រព័ន្ធគំរូស្តង់ដា (Generic Template) សម្រាប់ការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច" និង "នីតិវិធីនៃការចូលជាសមាជិកថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដើម្បីប្រើប្រាស់សេវានានានៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃថ្នាល CamDX"។

គួបញ្ជាក់ផងដែរថា នេះជាលើកទី ១ ដែលមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានរៀបចំសិក្ខាសាលាស្តីពី "ប្រព័ន្ធអេកូឡូស៊ីថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា" នេះឡើង ដើម្បីជំរុញការយល់ដឹង និង បង្កើនការចូលរួមប្រើប្រាស់ផលិតផលឌីជីថល ដែលស្ថិតក្នុងប្រព័ន្ធអេកូឡូស៊ីថ្នាល CamDX ដែលមានស្រាប់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅ៖

**(១)** បញ្ជ្រាបការយល់ដឹងឱ្យកាន់តែច្បាស់ពីសមិទ្ធផល និង យន្តការនៃការប្រើប្រាស់ថ្នាល CamDX របស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព,

(២) ជំរុញ និង បង្កើនការចូលរួមប្រើប្រាស់ផលិតផលឌីជីថល ដែលមានស្រាប់នៅក្នុងប្រព័ន្ធអេកូឡូស៊ីថ្នាល CamDX,

(៣) ផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ និង ច្បាស់លាស់ ដើម្បីឱ្យសាធារណជន និង តួអង្គពាក់ព័ន្ធអាចចូលរួមទាញយកផលប្រយោជន៍ជាអតិបរមាពីថ្នាល CamDX និង

(៤) លើកទឹកចិត្តដល់ក្រសួង ស្ថាប័ន ធ្វើការផ្លាស់ប្តូរ ឬ ចែករំលែកទិន្នន័យ (បើកទិន្នន័យគោល) និង ការធ្វើអន្តរប្រតិបត្តិការ នៅក្នុងប្រព័ន្ធអេកូឡូស៊ីថ្នាល CamDX សំដៅធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

ជារួម សិក្ខាសាលានេះបានឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការចូលរួមពីតួអង្គសំខាន់ៗទាំងវិស័យសាធារណៈ និង វិស័យឯកជនក្នុងការផ្លាស់ប្តូរ ឬ ចែករំលែកទិន្នន័យក្នុងប្រព័ន្ធអេកូឡូស៊ីថ្នាល CamDX ដែលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ច API និង សង្គមឌីជីថលនៅប្រទេសកម្ពុជា។ បន្ថែមពីនេះ, សិក្ខាសាលានេះបានលើកទឹកចិត្តដល់ ក្រសួង ស្ថាប័ន ដែលកំពុងគ្រប់គ្រងទិន្នន័យគោល ឱ្យចូលរួមចែករំលែកទិន្នន័យក្នុងប្រព័ន្ធអេកូឡូស៊ីថ្នាល CamDX ឱ្យបានកាន់តែច្រើន ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល និង សម្រួលដល់ប្រតិបត្តិការអាជីវកម្មនៃវិស័យឯកជន តាមទម្រង់ឌីជីថល ស្របតាមមុំទី ៥ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល។